**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ផ្ញើជូន**

លោកជំទាវ **អ៊ុក សារ៉េត**

*លោកជំទាវជាទីរាប់អាន,*

*ភរិយាខ្ញុំ និងរូបខ្ញុំបានទទួលដំណឹងដ៏ក្រៀមក្រំ និងក្តុកក្តួលបំផុត* ដែលឯកឧត្តម **មាស ក្រូច** ទីប្រឹក្សារាជរដ្ឋាភិបាល ត្រូវជាស្វាមីរបស់លោកជំទាវបានទទួលមរណភាពក្នុងជន្មាយុ ៨៥ ឆ្នាំ ដោយរោគាពាធ ។

មរណភាពរបស់ឯកឧត្តម គឺជាការបាត់បង់ស្វាមី បិតា ជីតាដែលប្រកបដោយព្រហ្មវិហារធម៌ និងជាការបាត់បង់នូវមិត្តរួមអាវុធតស៊ូរំដោះជាតិចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត និងបានរួមសុខរួមទុក្ខជាមួយគ្នាក្នុងការបំរើជាតិ និងប្រជាជនកម្ពុជារហូតដល់ថ្ងៃអវសាននៃជីវិត ។

ក្រៅពីនេះ ឯកឧត្តម **មាស ក្រូច** គឺជាថ្នាក់ដឹកនាំ និងជាសកម្មជន ១ រូប នៃក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជា ដែលបានរួមចំណែកជួយកសាងសមិទ្ធផលសង្គមនានាជួយលើកស្ទួយដល់ជីវភាពប្រជាជននៅតាមមូលដ្ឋានបន្សល់ទុកនូវស្នាដៃជាច្រើនសំរាប់កូនចៅជំនាន់ក្រោយ ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ *ភរិយាខ្ញុំ* និងរូបខ្ញុំ សូមចូលរួមចែករំលែកនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយលោកជំទាវ និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនក្មួយទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត ។

*ភរិយាខ្ញុំ* និងរូបខ្ញុំសូមឧទ្ទិសបួងសួងអោយដួងវិញ្ញាណក្ខន្ធឯកឧត្តម **មាស ក្រូច** បានចាប់កំណើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកជំទាវទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៧*

**ហ៊ុន សែន**